# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ / អនក្រ.បក / ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើត ខុទ្ទកាល័យនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១** : បង្កើត «ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ» ហៅកាត់ថា «ក.ប.ស» នៅអមខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។

**មាត្រា ២** : សមាសភាព និងរចនាសម្ព័ន្ធ នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រួមមាន ÷

- ប្រធាន និងអនុប្រធាន ក.ប.ស ត្រូវមានសមត្ថភាពខាងផ្នែកចំណេះវិជ្ជា និងនៅក្នុងការបំពេញការងារពិសេសតីការងារពាក់ព័ន្ធនឹងការវិភាគ និងការរៀបចំចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។
- សមាជិកយ៉ាងតិចប្រាំរូប ដែលត្រូវមានគុណសម្បត្តិ ចំណេះវិជ្ជា និងបទពិសោធន៍ការងារក្នុងវិស័យណាមួយនៃមុខជំនាញសេដ្ឋកិច្ច ហិរញ្ញវត្ថុ នីតិសាស្ត្រ ពាណិជ្ជកម្ម កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ឬ ឧស្សាហកម្ម ។
- មានអគ្គលេខាធិការមួយរូប សំរាបជាជំនួយអោយប្រធាន និងអនុប្រធាន ក.ប.ស នៅក្នុងការបំពេញការងារប្រចាំថ្ងៃ ។
- សមាជិក ក.ប.ស នីមួយៗ អាចមានមន្ត្រីជំនួយការផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយចំនួនពីរូប ដែលត្រូវមានសមត្ថភាពខាងផ្នែកចំណេះដឹងយ៉ាងហោចចាប់ពីថ្នាក់បរិញ្ញាប័ត្រឡើង ។

- ប្រធានកិត្តិយស ក.ប.ស មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។
- ប្រធាន ក.ប.ស មានឋានៈស្មើ រដ្ឋមន្ត្រី ។
- អនុប្រធាន ក.ប.ស មានឋានៈស្មើ រដ្ឋមន្ត្រី ។
- អគ្គលេខាធិការ ក.ប.ស មានឋានៈស្មើ រដ្ឋលេខាធិការ ។
- សមាជិក ក.ប.ស អាចមានឋានៈស្មើ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ។
- មន្ត្រីជំនួយការស្រាវជ្រាវ និងវិភាគគោលនយោបាយ អាចមានឋានៈស្មើ អគ្គនាយក អគ្គនាយករង ឬ ប្រធាននាយកដ្ឋាន ។
- ប្រធានកិត្តិយស ប្រធាន អនុប្រធាន សមាជិក អគ្គលេខាធិការ និងមន្ត្រីជំនួយការស្រាវជ្រាវ និងវិភាគគោលនយោបាយ នៃ ក.ប.ស ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យ ។

**មាត្រា ៣**: ក.ប.ស មានប្រធានកិត្តិយសម្នាក់ ដែលជ្រើសរើសពីក្នុងចំណោមឥស្សរជន ដែលមានគុណសម្បត្តិក្នុងការបំរើប្រទេសជាតិ មានបទពិសោធន៍ខ្ពស់ និងមានការទទួលស្គាល់នៅក្នុងមជ្ឈដ្ឋានជាតិ និងនៅលើឆាកអន្តរជាតិ ។

**មាត្រា ៤**: ភារកិច្ច និងមុខងារសំខាន់ៗរបស់ ក.ប.ស មានដូចតទៅ÷

- ពិនិត្យ និងរៀបចំឯកសារ និងសុន្ទរកថាសំខាន់ៗនានា ព្រមទាំងលើកឡើងគំនិតផ្តួចផ្តើមទាំងឡាយដែលមានចរិតជាចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រកែទំរង់ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិជូនប្រមុខរាជរដ្ឋាភិបាល ។
- ធ្វើជាសេនាធិការអោយនាយករដ្ឋមន្ត្រី នៅក្នុងការតាមដាន និងបូកសរុបការអនុវត្តន៍ការងារកែទំរង់ និងគំនិតផ្តួចផ្តើមនានាក្នុងផ្នែកសេដ្ឋកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញផ្ទាល់ ។
- ធ្វើជាសេនាធិការអោយនាយករដ្ឋមន្ត្រី នៅក្នុងការតាមដាន និងបូកសរុបរបាយការណ៍នានា ដែលពាក់ព័ន្ធនឹងការអនុវត្តន៍ផែនការប្រាំឆ្នាំ និងកម្មវិធីអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល ព្រមទាំងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីធានាអោយបាននូវសង្គតភាពនៅក្នុងគោលនយោបាយសេដ្ឋកិច្ចជាតិ ព្រមទាំងដើម្បីតំរង់ទិស និងបង្កើនល្បឿននៃការអនុវត្តន៍ផែនការ និងកម្មវិធីទាំងនោះ ។
- រៀបចំអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល សំដៅធានាអោយបាននូវគុណភាព និងសង្គតភាព នៃគោលនយោបាយសេដ្ឋកិច្ចជាតិ នៅក្នុង និងរវាងវិស័យនានា និងផ្តល់យោបល់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ចេញនូវទិសដៅច្បាស់លាស់ សំរាប់ការអនុវត្តន៍ដោយរលូននូវគោលនយោបាយ និងយុទ្ធសាស្ត្រនៃផែនការប្រាំឆ្នាំ និងកម្មវិធីវិនិយោគសាធារណៈ ។
- ស្នើឡើងនូវវិធានការជាក់ស្តែងនានា ក្នុងទិសដៅកែលំអការគ្រប់គ្រងសេដ្ឋកិច្ចជាតិ និងពង្រឹងអភិបាលកិច្ចល្អជូននាយករដ្ឋមន្ត្រីពិនិត្យ និងសំរេច ។
- បូកសរុប និងធ្វើរបាយការណ៍សង្ខេបជូនប្រមុខរាជរដ្ឋាភិបាលជ្រាប អំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ ហើយផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសំរបសំរួលដំណើរការនយោបាយសេដ្ឋកិច្ចជាតិ អោយស្របទៅតាមនិន្នាការវិវត្តន៍នៃសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ ។
- រៀបចំអោយមានជំនួបរវាង ក.ប.ស ជាមួយនាយករដ្ឋមន្ត្រី ដើម្បីទទួលបាននូវការវាយតម្លៃ និងការណែនាំនៅក្នុងទិសដៅធ្វើការកែលំអចាំបាច់នូវការងាររបស់ ក.ប.ស ។

**មាត្រា ៥ :** ដើម្បីអាចបំពេញមុខងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៤ ខាងលើ ជូនប្រមុខរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ ក.ប.ស ត្រូវមានតំណាងចូលរួមតាមដាននៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ដែលរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី និងដោយក្រសួង-ស្ថាប័ននានា នៅក្នុងទិសដៅសំរបសំរួលការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការកែទំរង់នានារបស់រាជរដ្ឋាភិបាល ។ គ្រប់ក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធទាំងអស់ របស់រាជរដ្ឋាភិបាលមានភារកិច្ចផ្តល់នូវឯកសារ ពត៌មាន និងកិច្ចសហការចាំបាច់នានាជូនដល់ ក.ប.ស ។

**មាត្រា ៦ :** ក.ប.ស បើកការប្រជុំរបស់ខ្លួនទៅតាមតម្រូវការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន និងតាមសេចក្តីបង្គាប់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា ៧ :** ក.ប.ស ប្រើប្រាស់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី នៅក្នុងក្របខ័ណ្ឌនៃថវិកាខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។ ក.ប.ស មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពជំនួយបរទេស និងពីប្រភពផ្សេងៗទៀត សំរាប់ចំណាយលើសេវារដ្ឋបាល និងសំរាប់បំពេញសេចក្តីត្រូវការក្នុងការផ្គត់ផ្គង់សំភារៈ បរិក្ខារ និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមការចាំបាច់នៅក្នុងគោលដៅធ្វើអោយបានប្រសើរដល់ការអនុវត្តន៍មុខងាររបស់ខ្លួន ។

**មាត្រា ៨ :** ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ។

**មាត្រា ៩ :** អនុក្រឹត្យលេខ ០១ / អនក្រ.បក / ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១០:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០១*

ហ៊ុន សែន

<u>ចម្លងជូន</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១០*
- *ឯកសារ- កាលប្បវត្តិ*